**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ១៤៤១៦ ប្រក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៥៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពីថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ សម្រាប់ជនបរទេសអន្តោប្រវេសន្ត
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៧៦ សហវ.ប្រក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកំណត់អាករទិដ្ឋាការ និងអាករទិដ្ឋាការរយៈពេលស្នាក់នៅបណ្តោះអាសន្ន សម្រាប់ជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._**

អនុញ្ញាតឱ្យក្រសួងមហាផ្ទៃ អនុវត្តការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាល ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

សេវារដ្ឋបាលដែលផ្តល់ដោយក្រសួងមហាផ្ទៃ ត្រូវបានរៀបចំជាកម្រងសេវារដ្ឋបាល ដែលមានរាយលម្អិតអំពីតម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវារដ្ឋបាលនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ២ ._**

ក្រសួងមហាផ្ទៃត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវារដ្ឋបាល ក្នុងនោះរួមមាន ÷ តារាងកម្រងសេវារដ្ឋបាល ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវារដ្ឋបាល និងការបង់កម្រៃសេវារដ្ឋបាល។

ក្រសួងមហាផ្ទៃត្រូវរៀបចំឱ្យមានកន្លែងទទួលពាក្យបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ មានការយឺតយ៉ាវហួសរយៈពេលអតិបរមានៃការផ្តល់សេវាជាដើម។

**ប្រការ៣ ._**

ក្រសួងមហាផ្ទៃមានភារកិច្ចប្រមូលចំណូលពីកម្រៃសេវារដ្ឋបាល។ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ ទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូលចូលថវិកាជាតិ និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៤ ._**

រាល់ការទទួលប្រាក់ចំណូលពីកម្រៃសេវារដ្ឋបាលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៥ ._**

ក្រសួងមហាផ្ទៃត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការនៅទីកន្លែងផ្តល់សេវា ដែលមានលក្ខណៈជាច្រកចេញចូលតែមួយ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ៦ ._**

អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ ត្រូវធ្វើរបាយការណ៍បូកសរុប ស្តីពីការអនុវត្តចំណូលប្រចាំខែនិងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៧ ._**

កម្រៃសេវារដ្ឋបាល ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបាន តាមការចាំបាច់ តាមរយៈប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨ ._**

ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម ÷

- ប្រកាសអន្តរក្រសួងលេខ ២០៨៧ ប្រក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ស្តីពីការកំណត់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ប្រកាសអន្តរក្រសួងលេខ ៣៦៦៦ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

- ប្រកាសអន្តរក្រសួងលេខ ៨០២៨ ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលកម្រងសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៦៦៦ ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គស្នងការ អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ០៤៤៦៩ ប្រ.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| I. អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | | | | |
| ក- កិច្ចការសញ្ជាតិ | | | | |
| 1 | ការស្នើសុំចូលសញ្ជាតិខ្មែរ | 2 000 000 ៛ | មិនកំណត់ | អចិន្ត្រៃយ៍ |
| 2 | ការស្នើសុំលះបង់សញ្ជាតិខ្មែរ | 300 000 ៛ | មិនកំណត់ | អចិន្ត្រៃយ៍ |
| 3 | ការស្នើសុំទាមទារសញ្ជាតិខ្មែរ | 400 000 ៛ | មិនកំណត់ | អចិន្ត្រៃយ៍ |
| ខ- កិច្ចការអត្រានុកូលដ្ឋាន | | | | |
| 4 | ការស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយប្រជាពលរដ្ឋខ្មែរ | 0 ៛ | 23ថ្ងៃ | អចិន្ត្រៃយ៍ |
| គ- កិច្ចការស្ថិតិប្រជាពលរដ្ឋ | | | | |
| 5 | ការផ្តល់សៀវភៅស្នាក់នៅ | 0 ៛ | 10ថ្ងៃ | អចិន្ត្រៃយ៍ |
| 6 | ទុតិយតា ឬ តតិយតាសៀវភៅស្នាក់នៅ | 0 ៛ | 10ថ្ងៃ | អចិន្ត្រៃយ៍ |
| 7 | ការស្នើសុំបន្ថែម ឬ បន្ថយសមាជិកគ្រួសារក្នុងសៀវភៅស្នាក់នៅ | 0 ៛ | 10ថ្ងៃ | អចិន្ត្រៃយ៍ |
| 8 | ការផ្តល់សៀវភៅគ្រួសារ | 0 ៛ | 15ថ្ងៃ | អចិន្ត្រៃយ៍ |

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 9 | ទុតិយតា ឬ តតិយតាសៀវភៅគ្រួសារ | 0 ៛ | 15ថ្ងៃ | អចិន្ត្រៃយ៍ |
| 10 | ការស្នើសុំបន្ថែម ឬ បន្ថយសមាជិកគ្រួសារក្នុងសៀវភៅគ្រួសារ | 0 ៛ | 15ថ្ងៃ | អចិន្ត្រៃយ៍ |
| ឃ-កិច្ចការអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | | | | |
| 11 | ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | 0 ៛ | 30ថ្ងៃ | 10ឆ្នាំ |
| 12 | ទុតិយតា ឬ តតិយតាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | 0 ៛ | 30ថ្ងៃ | 10ឆ្នាំ |
| ង-កិច្ចការលិខិតឆ្លងដែន | | | | |
| 13 | ការបន្តសុពលភាពលិខិតឆ្លងដែន | 10 $ | 5ថ្ងៃ | 2ឆ្នាំ |
| 14 | ការផ្តល់លិខិតឆ្លងដែនគំរូថ្មី (សម្រាប់មនុស្សចាស់ ៦៤ទំព័រ) | | | |
| | - សេវាធម្មតា | 100 $ | 20ថ្ងៃ | 10ឆ្នាំ |
| | - សេវាឆាប់រហ័សកម្រិតមធ្យម | 150 $ | 10ថ្ងៃ | 10ឆ្នាំ |
| | - សេវាឆាប់រហ័ស | 200 $ | 1ថ្ងៃ | 10ឆ្នាំ |
| 15 | ការផ្តល់លិខិតឆ្លងដែនគំរូថ្មី (សម្រាប់កូនក្មេង ៤៨ទំព័រ) | | | |
| | - សេវាធម្មតា | 80 $ | 20ថ្ងៃ | 5ឆ្នាំ |
| | - សេវាឆាប់រហ័សកម្រិតមធ្យម | 120 $ | 10ថ្ងៃ | 5ឆ្នាំ |
| | - សេវាឆាប់រហ័ស | 160 $ | 1ថ្ងៃ | 5ឆ្នាំ |

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| II. **អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន** | | | | |
| 16 | ការតម្កល់ទុកឯកសារស្នើសុំបង្កើតអង្គការ សមាគម ឬ សហគមន៍ | 300 000 ៛ | 30ថ្ងៃ | អចិន្ត្រៃយ៍ |
| 17 | ការបើកសាខា ការកែសម្រួលរចនាសម្ព័ន្ធ និងលក្ខន្តិកៈរបស់អង្គការ សមាគម ឬ សហគមន៍ | 200 000 ៛ | 30ថ្ងៃ | អចិន្ត្រៃយ៍ |
| III. **អគ្គស្នងការនគរបាលជាតិ** | | | | |
| 18 | ការផ្តល់ប័ណ្ណប្រើប្រាស់រំសេវ គ្រឿងផ្ទុះ | 800 000 ៛ | 10ថ្ងៃ | 1ឆ្នាំ |
| 19 | ការផ្តល់ប័ណ្ណប្រើប្រាស់អាវុធលក្ខណៈបុគ្គល | 50 000 ៛ | 10ថ្ងៃ | 1ឆ្នាំ |
| 20 | សេវាការពារដឹកជញ្ជូនរំសេវ គ្រឿងផ្ទុះ (1នាក់) | 150 000 ៛ | 1ថ្ងៃ | 1លើក |
| 21 | ការផលិតត្រាទឹក | 100 000 ៛ | 3ថ្ងៃ | អចិន្ត្រៃយ៍ |
| 22 | ការផលិតត្រាស្ងួត | 200 000 ៛ | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 23 | ការស្នើសុំលិខិតអនុញ្ញាតបើកក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន | 2 000 000 ៛ | 30ថ្ងៃ | អចិន្ត្រៃយ៍ |
| 24 | ការស្នើសុំលិខិតអនុញ្ញាតជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនរបស់សហគ្រាស ឬ គ្រឹះស្ថាននានា | 500 000 ៛ | 30ថ្ងៃ | អចិន្ត្រៃយ៍ |
| 25 | ការស្នើសុំលិខិតបញ្ជាក់ និងបន្តកិច្ចសន្យាជាថ្មីរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន | 400 000 ៛ | 30ថ្ងៃ | 3ឆ្នាំ |
| 26 | ការស្នើសុំលិខិតបញ្ជាក់ និងបន្តកិច្ចសន្យាជាថ្មីរបស់សហគ្រាស ឬ គ្រឹះស្ថាននានា | 100 000 ៛ | 30ថ្ងៃ | 3ឆ្នាំ |

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 27 | ការស្នើសុំផ្លាស់ប្តូរអគ្គនាយក ឬ ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន | 500 000 ៛ | 30ថ្ងៃ | រហូតមានការផ្លាស់ប្តូរថ្មី |
| 28 | ការស្នើសុំផ្លាស់ប្តូរស្លាកសញ្ញា (Logo) នៃក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន | 200 000 ៛ | 30ថ្ងៃ | រហូតមានការផ្លាស់ប្តូរថ្មី |
| 29 | ការស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់រថយន្តដឹកជញ្ជូនប្រាក់ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃរបស់សន្តិសុខគ្រប់ប្រភេទ | 1 500 000 ៛ | 30ថ្ងៃ | 3ឆ្នាំ |
| 30 | កម្រៃសេវានៃកិច្ចសហការរវាងក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន ជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលអនុលោមតាមកិច្ចសន្យារវាងភាគីទាំងពីរ | | 15ថ្ងៃ | 3ឆ្នាំ |
| | - ចំនួនបុគ្គលិកតិចជាង 100 នាក់ | 1,7 $ / 1នាក់ / 1ខែ | | |
| | - ចំនួនបុគ្គលិកចាប់ពី 100 នាក់ ដល់ 299 នាក់ | 1,5 $ / 1នាក់ / 1ខែ | | |
| | - ចំនួនបុគ្គលិកចាប់ពី 300 នាក់ ដល់ 499 នាក់ | 1,4 $ / 1នាក់ / 1ខែ | | |
| | - ចំនួនបុគ្គលិកចាប់ពី 500 នាក់ ដល់ 999 នាក់ | 1,2 $ / 1នាក់ / 1ខែ | | |
| | - ចំនួនបុគ្គលិកចាប់ពី 1 000 នាក់ ឡើងទៅ | 1 $ / 1នាក់ / 1ខែ | | |
| 31 | កម្រៃសេវានៃកិច្ចសហការរវាងសហគ្រាស ឬ គ្រឹះស្ថាននានា ជាមួយស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលអនុលោមតាមកិច្ចសន្យារវាងភាគីទាំងពីរ | | 15ថ្ងៃ | 3ឆ្នាំ |
| | - ចំនួនបុគ្គលិកចាប់ពី 1 នាក់ ដល់ 49 នាក់ | 1 $ / 1នាក់ / 1ខែ | | |
| | - ចំនួនបុគ្គលិកចាប់ពី 50 នាក់ ឡើងទៅ | 2 $ / 1នាក់ / 1ខែ | | |

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 32 | ការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះ ÷ | | | |
| | - ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនដែលផ្តល់សេវាសន្តិសុខ ដោយគ្មានការអនុញ្ញាតពីក្រសួងមហាផ្ទៃ | 20 000 000 ៛ | ភ្លាមៗ | |
| | - សហគ្រាស ឬ គ្រឹះស្ថាននានាដែលជ្រើសរើសសន្តិសុខឯកជន ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលរាជធានី ខេត្ត | 10 000 000 ៛ | ភ្លាមៗ | |
| IV. **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** | | | | |
| 33 | ការផ្តល់ប័ណ្ណឆ្លងដែន | 20 000 ៛ | 3ថ្ងៃ | 2ឆ្នាំ |
| 34 | ការផ្តល់ទិដ្ឋាការ | | | |
| | - ទិដ្ឋាការការទូត (A) | មិនយកអាករ | ភ្លាមៗ | 3ខែ |
| | - ទិដ្ឋាការផ្លូវការ (B) | មិនយកអាករ | ភ្លាមៗ | 3ខែ |
| | - ទិដ្ឋាការបោរីភាព (C) | មិនយកអាករ | ភ្លាមៗ | 3ខែ |
| | - ទិដ្ឋាការឆ្លងកាត់ (D) | 15 $ | ភ្លាមៗ | 7ថ្ងៃ |
| | - ទិដ្ឋាការធម្មតា (E) | 35 $ | ភ្លាមៗ | 3ខែ |
| | - ទិដ្ឋាការធម្មតារយៈពេលវែង ១ឆ្នាំ (E1) | 50 $ | ភ្លាមៗ | 1ឆ្នាំ |
| | - ទិដ្ឋាការធម្មតារយៈពេលវែង ២ឆ្នាំ (E2) | 75 $ | ភ្លាមៗ | 2ឆ្នាំ |

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | - ទិដ្ឋាការធម្មតារយៈពេលវែង ៣ឆ្នាំ (E3) | 100 $ | ភ្លាមៗ | 3ឆ្នាំ |
| | - ទិដ្ឋាការចេញ (Ex) | 30 $ | ភ្លាមៗ | 7ថ្ងៃ |
| | - ទិដ្ឋាការពិសេស (K) | មិនយកអាករ | ភ្លាមៗ | សុពលភាពលិខិតឆ្លងដែន |
| | - ទិដ្ឋាការទេសចរណ៍ (T) | 30 $ | ភ្លាមៗ | 3ខែ |
| | - ទិដ្ឋាការទេសចរណ៍រយៈពេលវែង ១ឆ្នាំ (T1) | 40 $ | ភ្លាមៗ | 1ឆ្នាំ |
| | - ទិដ្ឋាការទេសចរណ៍រយៈពេលវែង ២ឆ្នាំ (T2) | 60 $ | ភ្លាមៗ | 2ឆ្នាំ |
| | - ទិដ្ឋាការទេសចរណ៍រយៈពេលវែង ៣ឆ្នាំ (T3) | 80 $ | ភ្លាមៗ | 3ឆ្នាំ |
| 35 | ការផ្តល់ទិដ្ឋាការបន្តការស្នាក់នៅបណ្តោះអាសន្ន | | | |
| | - រយៈពេល 1ខែ | 30 $ | 7ថ្ងៃ | 1ខែ |
| | - រយៈពេល 3ខែ | 60 $ | 7ថ្ងៃ | 3ខែ |
| | - រយៈពេល 6ខែ | 100 $ | 15ថ្ងៃ | 6ខែ |
| | - រយៈពេល 12ខែ | 180 $ | 15ថ្ងៃ | 12ខែ |
| | - រយៈពេល 24ខែ | 340 $ | 15ថ្ងៃ | 24ខែ |
| 36 | ផ្តល់លិខិតបើកផ្លូវ ជូនជនបរទេសអន្តោប្រវេសន្ត | 50 000 ៛ | 7ថ្ងៃ | 3ខែ |
| 37 | ពន្យារពេលលិខិតបើកផ្លូវ ជូនជនបរទេសអន្តោប្រវេសន្ត | 19 000 ៛ | 7ថ្ងៃ | 3ខែ |

| ល.រ | ប្រភេទសេវា | តម្លៃសេវា | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 38 | ផ្តល់ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជូនជនបរទេសអន្តោប្រវេសន្ត | 250 000 ៛ | 30ថ្ងៃ | 2ឆ្នាំ |
| 39 | ទុតិយតាប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជូនជនបរទេសអន្តោប្រវេសន្ត | 250 000 ៛ | 30ថ្ងៃ | 2ឆ្នាំ |
| 40 | ពន្យារពេលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ជូនជនបរទេសអន្តោប្រវេសន្ត | 250 000 ៛ | 30ថ្ងៃ | 2ឆ្នាំ |
| 41 | ការពិន័យអន្តរការណ៍ជាប្រាក់ ចំពោះ ÷ | | | |
| | - ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់ | 10 $ / 1ថ្ងៃ | ភ្លាមៗ | |
| | - ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលធ្វើសកម្មភាពផ្ទាល់ខ្លួនខុសពីប្រភេទទិដ្ឋាការដែលបានផ្តល់ជូន | 100 $ | ភ្លាមៗ | |
| | - ពលករបរទេស ដែលគ្មានប័ណ្ណការងារចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 500 000 ៛ | ភ្លាមៗ | |